ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 04 / 2013
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN Rada

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូ អុត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

## សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSE
Arthur VERCKEN
Jacques VERGÈS

## ១. សេចក្តីផ្តើម

១ កាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 "ដោយពិនិត្យទៅលើឯកសារជាច្រើននៅក្នុងសំណុំរឿង និងឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលគាត់បានមើងផ្ទាល់ និង/ឬគាត់ជាអ្នកនិពន្ធ"[1]។ អ្នកជំនាញដែលមានរហស្សនាម TCE-33 ត្រូវបានកំណត់កាលបរិច្ឆេទដើម្បីឱ្យមកផ្តល់សក្ខីកម្មក្នុងពេលឆាប់ៗនេះ។ សហព្រះរាជអាជ្ញាស្នើសុំឱ្យកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាសាក្សីជំនាញ[2]។ នៅក្នុងសារណាដែលបានដាក់ជាច្រើន ក្រុមមេធាវីការពារក្តីបានជំទាស់នឹងការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 ឱ្យធ្វើជាអ្នកជំនាញ ដោយផ្អែកលើមូលហេតុថា អ្នកជំនាញដែលមានរហស្សនាម TCE-33 មិនឯករាជ្យ ឬលម្អៀង ដោយសារតែអ្នកជំនាញរូបនេះ ធ្លាប់បានធ្វើការងារឱ្យការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") និងការិយាល័យសហចៅក្រមស៊ើប

---

[1] ការប្រកាសអំពីសាក្សីដែលគ្រោងផ្តល់សក្ខីកម្មនាពេលខាងមុខ ឯកសារលេខ E236/2 ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ២។

[2] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥ ឯកសារ E9/4 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ៨។ ឧបសម្ព័ន្ធ ១៖ សំណើបង្គាប់ឱ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ ឯកសារ E9/4.1 (បានកំណត់អត្តសញ្ញាណសាក្សីដែលមានរហស្សនាម P-037 និងក្រោយមកត្រូវបានផ្តល់រហស្សនាមជា TCE-33 ថាជាអ្នកជំនាញ)។ ឧបសម្ព័ន្ធ២៖ បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព ឯកសារ E9/4.1 ទំព័រ២ (កំណត់អត្តសញ្ញាណសាក្សីដែលមានរហស្សនាម P-037 ថាជាអ្នកជំនាញ)។ សេចក្តីសង្ខេបអំពី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន ៨០ ឯកសារ E9/13.1 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ៣៣ និង ៣៤ (សង្ខេបសក្ខីកម្មដែលស្នើសុំរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33)។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសេចក្តីណែនាំរបស់អង្គជំនុំជម្រះនៅមុនសវនាការបឋមដែលពាក់ព័ន្ធទៅនឹងសាក្សីដែលបានស្នើសុំ ឯកសារ E93/3 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។ សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យស្តាប់អ្នកជំនាញ ២រូប និងសាក្សី ១៣រូប បន្ថែម នៅក្នុងដំណាក់កាលដំបូងនៃសវនាការ និងការជូនដំណឹងអំពីចេតនាដាក់ឈុតវីដេអូខ្លីៗចំនួន៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ៨៧(៤) ឯកសារលេខ E93/7 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ ("សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់សាក្សីបន្ថែម") កថាខណ្ឌ៣។ សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ ក) ឯកសារលេខ E218/2 ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២។

អង្កេត "ក.ស.ច.ស"[3]។ តាមរយៈសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះនឹងលើកឡើងអំពីមូលដ្ឋាន ដែលខ្លួននឹងត្រូវស្ដាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33។

## ២. សារណា

២ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ្នកជំនាញដែលមានរហស្សនាម TCE-33 គឺជាអ្នកជំនាញ ដែល៖

> ត្រូវបានគេចាត់ទុកជាទូទៅយ៉ាងទូលំទូលាយថាជាអ្នកជំនាញដែលមានការចេះដឹងជ្រាលជ្រៅជាងគេមួយរូប ក្នុងចំណោមអ្នកជំនាញនានាទូទាំងពិភពលោកអំពីប្រវត្តិសាស្ត្រ, គោលនយោបាយ, ការវិវឌ្ឍន៍, និងរចនាសម្ព័ន្ធនៃសិទ្ធិអំណាចរបស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ, និងអំពីព្រឹត្តិការណ៍ផ្សេងៗ ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបានទទួលសញ្ញាប័ត្រ BA, MA (នៅ Cornell) និងសញ្ញាប័ត្រ PhD (នៅទីក្រុងឡុងដុង)ហើយបច្ចុប្បន្ននេះ ជាអ្នកធ្វើបកថាស្ដីពីនយោបាយនៃអាស៊ីអាគ្នេយ៍ នៅសាលាបូព៌ា និងការសិក្សាស្រាវជ្រាវអំពីទ្វីបអាហ្វ្រិក នៅសាកលវិទ្យាល័យទីក្រុងឡុងដុង។ គាត់គឺជាសមាជិកនៃគណៈនាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលចេះនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ[4]។

---

[3] សេចក្ដីជំទាស់របស់ ខៀវ សំផន ទៅនឹងការចូលខ្លួនរបស់អ្នកជំនាញមួយចំនួន ឯកសារលេខ E9/4/10 ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១១។ សេចក្ដីសង្កេតបឋម របស់ នួន ជា ទាក់ទងនឹងសាក្សីដែលភាគីបានស្នើសុំ ឯកសារលេខ E9/4/12 ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៧។ ដោយសារតែបច្ច័យនៃការបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងអស់ប្រឆាំងនឹង អៀង សារី បន្ទាប់ពីមរណភាពរបស់គាត់ (សេចក្ដីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ឯកសារលេខ E270/1 ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣), សំណើសុំរបស់មេធាវីការពារក្ដីរបស់អៀង សារី ជាបន្តបន្ទាប់ដែលមិនទាន់សម្រេចលើផ្នែកទាំងមូល ឬផ្នែកណាមួយនៅពេលមរណភាពរបស់គាត់ គឺមិនចាំបាច់៖ សំណើរបស់ អៀង សារី ស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញដែលមានរហស្សនាម TCE-33 ឯកសារលេខ E236/2/2 ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២។ ការជំទាស់ជាបឋមរបស់ អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល៣០ថ្ងៃ ឯកសារ E9/4/9 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៧ និងសេចក្ដីអង្កេតរួមរបស់ អៀង សារី ស្ដីពីសាក្សី និងអ្នកជំនាញមួយចំនួនដែលសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី និង នួន ជា បានស្នើសុំកោះហៅបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្ដោះអាសន្ន ឯកសារលេខ E93/12 ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៣។

[4] សេចក្ដីសង្ខេបអំពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ ឯកសារលេខ E9/13.1 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ៣៣ និង ៣៤។

៣ សហព្រះរាជអាជ្ញា បានបង្ហាញថា អ្នកជំនាញដែលមានរហស្សនាម TCE-33 គឺជាអ្នកនិពន្ធសៀវភៅជាច្រើន អត្ថបទសិក្សា និងឯកសារផ្សេងៗស្តីពីខ្មែរក្រហម បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) និងកម្ពុជាប្រជាធិបតេយ្យ។ អស់រយៈពេលជាង៣០ឆ្នាំ អ្នកជំនាញដែលមានរហស្សនាម TCE-33 បានធ្វើការពិនិត្យយ៉ាងទូលំទូលាយទៅលើឯកសារដែលទាក់ទងនឹង ប.ក.ក និងកម្ពុជាប្រជាធិបតេយ្យ ដោយសហការជាមួយអ្នកជំនាញកម្ពុជាជាច្រើនរូបផ្សេងទៀត និងបានជួបសម្ភាសន៍ជាមួយកម្មាភិបាល ប.ក.ក និងប្រជាជនកម្ពុជាជាច្រើនដែលទទួលរងពីព្រឹត្តិការណ៍នានាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកជំនាញដែលមានរហស្សនាម TCE-33 ក៏បានសម្ភាសន៍មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក/កម្ពុជាប្រជាធិបតេយ្យ រួមមាន អៀង សារី និង ខៀវ សំផន។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 គឺសំខាន់ចាំបាច់ ដើម្បីជួយអង្គជំនុំជម្រះក្នុងការស្វែងរកការពិតទាក់ទិននឹងបញ្ហានានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[5]។

៤ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ្នកជំនាញដែលមានរហស្សនាម TCE-33 គឺជាអ្នកជំនាញដែលមានការចេះដឹងជ្រាលជ្រៅជាងគេមួយរូប ក្នុងចំណោមអ្នកជំនាញនានាទូទាំងពិភពលោកអំពីប្រវត្តិសាស្រ្ត, គោលនយោបាយ, ការវិវឌ្ឍន៍, និងរចនាសម្ព័ន្ធនៃសិទ្ធិអំណាចរបស់ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏ជាប្រភពយោងនាំមុខម្នាក់អំពីភាសាខ្មែរ និងជាពិសេសវាក្យស័ព្ទអំពី ប.ក.ក ហើយគាត់នឹងជួយដល់អង្គជំនុំជម្រះក្នុងការបញ្ជាក់បំភ្លឺអំពីអត្ថន័យនៃពាក្យពេចន៍គន្លឹះ ដែលបានប្រើនៅក្នុងឯកសារខ្មែរក្រហម[6]។ សហព្រះរាជអាជ្ញាស្នើសុំឱ្យសួរដេញដោលអ្នកជំនាញដែលមានរហស្សនាម TCE-33 នៅចំពោះមុខអង្គជំនុំជម្រះអំពី៖

> ប្រវត្តិរបស់ ប.ក.ក, អំពីដំណើរការប្រព្រឹត្តទៅ និងរចនាសម្ព័ន្ធនៃសិទ្ធិអំណាចរបស់ ប.ក.ក និងកងទ័ពបដិវត្តន៍កម្ពុជា, ដើមកំណើត និងការវិវឌ្ឍន៍នៃគោលនយោបាយរបស់

---

[5] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់សាក្សីបន្ថែម, ឯកសារ E93/7។

[6] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់សាក្សីបន្ថែម, ឯកសារ E93/7 កថាខណ្ឌ១៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ១ ភ្ជាប់នឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារលេខ E93/3.1 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ៧ (កំណត់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ថាមានលក្ខណៈពាក់ព័ន្ធទៅនឹងផ្នែកនីមួយៗនៃផ្នែកទាំងបួនដំបូងនៃសំណុំរឿង០០២/០១ ដូចដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះក្នុងអំឡុងពេលកិច្ចប្រជុំគ្រប់គ្រងតុលាការលើកទី១)។

ប.ក.ក ស្តីពីវណ្ណៈ, ការធ្វើសមូហភាវនីយកម្ម និងការធ្វើពលកម្មដោយបង្ខំ និងអំពីការកំណត់អត្តសញ្ញាណ និងការគាបសង្កត់ខ្មាំង ដែលបណ្តាលឱ្យកើតមាននូវគោលនយោបាយឧក្រិដ្ឋ ដូចដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, អំពីឧបករណ៍សន្តិសុខរបស់ ប.ក.ក/កម្ពុជាប្រជាធិបតេយ្យ និងការមិនបានយកចិត្តទុកដាក់របស់មជ្ឈិមបក្សចំពោះឧបករណ៍សន្តិសុខ, អំពីការវិវឌ្ឍន៍នៃការបោសសម្អាតនៅក្នុង និងក្រៅរបបនេះ។ អំពីសិទ្ធិអំណាចជាក់ស្តែង និងសិទ្ធិអំណាចតាមផ្លូវច្បាប់របស់ជនជាប់ចោទ, អំពីការប្រើប្រាស់របស់ខ្មែរក្រហមនូវវាក្យស័ព្ទពិសេសមួយ, និងអំពីគោលនយោបាយរបស់ ប.ក.ក ចំពោះពុទ្ធសាសនិក ជនជាតិវៀតណាម និងជនជាតិចាម, [បន្ថែមពីលើនេះ] បទសម្ភាសន៍ដែលលោកស្រង់ពីជនជាប់ចោទ និងពីសមាជិក ប.ក.ក ដទៃទៀត និងដែលបានស្នើសុំឱ្យឆ្លើយថាភូតិលើកំណត់ហេតុនៃការធ្វើសម្ភាសន៍ទាំងនោះ[7]។

៥ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ពីមុនយ៉ាងច្បាស់អំពីភាពស្មុគស្មាញរបស់ខ្លួនក្នុងការកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 ដោយផ្អែកលើមូលដ្ឋានថា សក្ខីកម្មរបស់គាត់ទំនងជាត្រូវបានជំទាស់ និងទំនងជាធ្វើឱ្យកិច្ចដំណើរការនីតិវិធីអូសបន្លាយយូរខ្លាំង[8]។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាលើកឡើងថា៖

> ប្រជាជននៅក្នុងពិភពលោក ប្រសិនណាមានមនុស្សណាម្នាក់ត្រូវមកនិយាយអំពីមនោគមវិជ្ជាកុម្មុយនីស្ត ពាក់ព័ន្ធទៅនឹងបក្សកុម្មុយនីស្តកម្ពុជា គឺគាត់សំខាន់ណាស់ ហើយគាត់ក៏ជាមនុស្សម្នាក់ដែលធ្វើការសម្ភាសន៍ជាមួយនឹងជនជាប់ចោទនោះផងដែរ[9]។

៦ មេធាវីការពារ ខៀវ សំផន ជំទាស់នឹងការបង្ហាញខ្លួនរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាសាក្សីជំនាញ ដោយផ្អែកលើមូលដ្ឋានការជាប់ពាក់ព័ន្ធពីមុនរបស់គាត់ និងតវ៉ាថា ការកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 នឹង "បង្ហាញយ៉ាងច្បាស់នូវភាពលម្អៀង និងភាពអត្តនោម័តរបស់អង្គជំនុំជម្រះ"[10]។ មេធាវីការពារក្តី នួន ជា ក៏បាន

---

[7] សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ ឯកសារលេខ E9/13.1 ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ទំព័រ៣៦-៣៧។

[8] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ទំព័រ ១៤។

[9] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ទំព័រ ១៧។

[10] សេចក្តីជំទាស់របស់ ខៀវ សំផន ទៅនឹងការចូលខ្លួនរបស់អ្នកជំនាញមួយចំនួន ឯកសារលេខ E9/4/10 ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១១។

យល់ស្របគ្នាថា អ្នកជំនាញដែលមានរហស្សនាម TCE-33 មិនមានលក្ខណៈសម្បត្តិធ្វើជាអ្នកជំនាញបានទេ ដោយសារតែ "ការជាប់ពាក់ព័ន្ធកាលពីមុន និងនាពេលបច្ចុប្បន្នរបស់អ្នកទាំងនេះ ជាមួយអង្គភាពណាមួយនៃសាលាក្តីនេះ ជាពិសេសជាមួយ ក.ស.ព និងការិយាល័យសហចៅក្រមស៊ើបអង្កេត"[11]។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តី យល់ស្របថាអ្នកជំនាញដែលមានរហស្សនាម TCE-33 គឺ "ជាសាក្សីដ៏សំខាន់ដូចមូលហេតុដែលសហព្រះរាជអាជ្ញាបានបញ្ជាក់"[12]។

៧ ទោះបីជាទទួលស្គាល់ថា អ្នកជំនាញដែលមានរហស្សនាម TCE-33 ធ្លាប់បានធ្វើការងារឱ្យ ក.ស.ព ក្នុងតំណែងជាអ្នកវិភាគ និងអ្នកស៊ើបអង្កេត និងធ្លាប់ធ្វើការងារឱ្យក.ស.ច.ស នៅក្នុងតំណែងជាអ្នកពិគ្រោះយោបល់ក៏ដោយ ក៏សហព្រះរាជអាជ្ញាតវ៉ាថា៖

> ដោយមិនគិតពីការជាប់ទំនាក់ទំនងអំពីវិជ្ជាជីវៈកាលពីមុន ឬបច្ចុប្បន្នជាមួយនឹងស្ថាប័នរបស់តុលាការ សាក្សីជំនាញនានាត្រូវបានតម្រូវ និងរំពឹងទុកថា ត្រូវផ្តល់សក្ខីកម្មឱ្យបានប្រកបដោយអព្យាក្រិត្យភាពជាទីបំផុត ហើយត្រូវផ្តល់ចម្លើយ និងទាញសេចក្តីសន្និដ្ឋានដោយឯករាជ្យ និងដោយមិនមានភាពលំអៀង[13]។

៨ សហព្រះរាជអាជ្ញាបានអះអាងថា ទោះបីជាអ្នកជំនាញដែលមានរហស្សនាម TCE-33 ធ្លាប់ជាសមាជិកមួយរូបរបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏សាក្សីរូបនេះធ្លាប់បានពាក់ព័ន្ធពីមុននៅក្នុងការស៊ើបអង្កេតរបស់ ក.ស.ច.ស ដែលជាការិយាល័យឯករាជ្យនៅក្នុង អ.វ.ត.ក។ ការជាប់ទាក់ទងរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 នៅក្នុងបទសម្ភាសន៍ជាមួយសាក្សីមួយចំនួន មិនគួរធ្វើឱ្យរាំងស្ទះដល់ការជ្រើសរើសគាត់ជាអ្នកជំនាញនោះទេ។ នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាលើកឡើងថា ភាពមិនលម្អៀងរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 អាចនឹងត្រូវសួរដេញដោលដោយភាគីនានា ប្រសិនបើចាំបាច់ ក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្មរបស់គាត់[14]។

---

[11] សេចក្តីសង្ខេបបឋមទាក់ទងនឹងសាក្សីដែលភាគីបានស្នើសុំ ឯកសារលេខ E9/4/12 ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៧។

[12] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ទំព័រ ២១។

[13] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់សាក្សីបន្ថែម, ឯកសារ E93/7 កថាខណ្ឌ ៧។

[14] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់សាក្សីបន្ថែម, ឯកសារ E93/7 កថាខណ្ឌ ៨-១០។

៩ ដោយពិចារណាទៅលើសេចក្ដីសម្រេចរបស់ ក.ស.ច.ស ដែលមិនស្ដាប់អ្នកជំនាញដែលមានរហស្សនាម TCE-33, សហព្រះរាជអាជ្ញាសន្និដ្ឋានថា ក.ស.ច.ស គ្រាន់តែលើកពេលនៃការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញឱ្យមកនៅដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ។ ក.ស.ច.ស បានដាក់ស្លាកដែលបោះពុម្ពផ្សាយរបស់អ្នកជំនាញផ្សេងដែលត្រូវបានស្នើសុំទៅក្នុងសំណុំរឿង ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាមានប្រយោជន៍ក្នុងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញទាំងនោះ[15]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនគួរបដិសេធអ្នកជំនាញដែលមានរហស្សនាម TCE-33 ដោយផ្អែកលើមូលដ្ឋានថា គាត់មិនត្រូវបានសម្ភាសន៍នៅក្នុងដំណាក់កាលស៊ើបអង្កេតនោះទេ។

១០ បន្ថែមពីលើនេះ និងនៅក្នុងកម្រិតអប្បបរមា ការពិចារណាខាងលើ មិនបានបដិសេធចោលអ្នកជំនាញដែលមានរហស្សនាម TCE-33 ពីការផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីលើអង្គហេតុនោះទេ[16]។ សហព្រះរាជអាជ្ញា កត់សម្គាល់ឃើញថា អ្នកជំនាញដែលមានរហស្សនាម TCE-33 បានធ្វើបទសម្ភាសន៍យ៉ាងច្រើនជាមួយ អៀង សារី និង ខៀវ សំផន ហើយអ្នកជំនាញរូបនេះ "ស្ថិតក្នុងគោលជំហរដ៏ពិសេសគ្មានពីរសម្រាប់ការផ្ទៀងផ្ទាត់នៅលើកំណត់ហេតុរបស់គាត់ ចំពោះបទសម្ភាសន៍ទាំងនេះ និងផ្ដល់នូវការចងចាំឡើងវិញបន្ថែម"[17]។

១១ មេធាវីការពារក្ដី នួន ជា ក៏បានកំណត់អត្តសញ្ញាណអ្នកជំនាញដែលមានរហស្សនាម TCE-33 ថាជាអ្នកជំនាញនាំមុខមួយរូបអំពីប្រទេសកម្ពុជា ប៉ុន្តែបានចាត់ថ្នាក់សក្ខីកម្មរបស់គាត់ថាពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ ក.ស.ច.ស ជាជាងពាក់ព័ន្ធនឹងបញ្ហាអង្គហេតុនានានៅពេលជំនុំជម្រះក្ដី។ មេធាវីការពារក្ដីលើកឡើងថា អ្នកជំនាញដែលមានរហស្សនាម TCE-33 គួរត្រូវបានចាត់ថ្នាក់ជាសាក្សីលើអង្គហេតុទើបសមស្របជាង ដោយពិចារណាលើការយល់ដឹង

---

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារលេខ E93/3 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១៤ ដែលដកស្រង់ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងអ្នកជំនាញ ឯកសារលេខ D281/3 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ៥ និង ៨។

[16] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្ដាប់សាក្សីបន្ថែម, ឯកសារ E93/7 កថាខណ្ឌ ៨។

[17] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្ដាប់សាក្សីបន្ថែម, ឯកសារ E93/7 កថាខណ្ឌ ១៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ១ ភ្ជាប់នឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារលេខ E93/3.1 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៧ (កត់សម្គាល់ឃើញថា អ្នកជំនាញដែលមានរហស្សនាម TCE-33 បានសម្ភាសន៍កម្មាភិបាលប.ក.កជាច្រើនរូប)។

របស់គាត់នៅក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ប៉ុន្តែមេធាវីការពារក្តីទទួលស្គាល់ថា គាត់គួរត្រូវបានសួរដេញដោលអំពី "ប្រធានបទទាំងអស់នៅក្នុងសវនាការនេះ"[18]។ មេធាវីការពារក្តី នួន ជា បានពិនិត្យបញ្ជីឈ្មោះសាក្សីឡើងវិញឃើញថា អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាបុគ្គលមួយរូបដ៏ "សំខាន់" សម្រាប់រឿងក្តីរបស់ខ្លួន[19]។

## ៣. សំអាងហេតុ

១២ កាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ក.ស.ច.ស បានសម្រេចមិនស្តាប់ចម្លើយអ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាអ្នកជំនាញនោះទេ ដោយផ្អែកលើមូលដ្ឋានថា ចម្លើយរបស់គាត់ ដដែល ទៅនឹងព័ត៌មានដែល មានរួចហើយនៅក្នុងសំណុំរឿង ដូច្នេះនឹងនាំឱ្យមានការពន្យារពេលមិនសមហេតុផល[20]។ បញ្ហានេះត្រូវបានកត់សម្គាល់ឃើញថា ដោយសារតែអ្នកជំនាញដែលមានរហស្សនាម TCE-33 គឺជាសមាជិករបស់ ក.ស.ច.ស ដូចនេះ "វានឹងមិនមែនជាផលប្រយោជន៍ប្រសើរខាងយុត្តិធម៌ទេ ប្រសិនបើចាត់តាំង[អ្នកជំនាញដែលមានរហស្សនាម TCE-33] ជាអ្នកជំនាញ ដែលកំណត់ដោយវិធាន ៣១ នៃវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនេះ"[21]។ ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត បានកត់សម្គាល់ឃើញថា អ្នកជំនាញដែលមានរហស្សនាម TCE-33 នៅតែអាចផ្តល់សក្ខីកម្មតាមសំណើរបស់ភាគីនានា ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍[22]។ អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់អំពីការបដិសេធរបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់មេធាវីការពារក្តី អៀង សារី ដើម្បីមោឃភាពកិច្ចស៊ើបសួរទាំងអស់ ដែលធ្វើឡើងដោយអ្នកជំនាញដែលមាន

---

[18] សេចក្តីសង្កេតបឋមទាក់ទងនឹងសាក្សីដែលភាគីបានស្នើសុំ ឯកសារ E9/4/12 ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៧។ ប្រតិចារិក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ ២១។

[19] សេចក្តីសង្ខេបអំពីការស្នើសុំសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់ នួន ជា ឯកសារលេខ E93/4.3 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៤០-៤១ (បានបញ្ជាក់ថា អ្នកជំនាញដែលមានរហស្សនាម TCE-33 អាចផ្តល់ឱ្យ "ការយល់ច្បាស់លាស់ចំពោះកិច្ច និងគុណសម្បត្តិនៃការស៊ើបអង្កេតរបស់ ក.ស.ច.ស នៅក្នុងសំណុំរឿង០០២")។ *សូមមើលផងដែរ* សំណើសុំរបស់ នួន ជា បន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារលេខ E93/9 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ និងឧបសម្ព័ន្ធ E93/9.1 ទំព័រ ១១-១២។

[20] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងអ្នកជំនាញ ឯកសារលេខ D281/3 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ("ដីកាសម្រេចរបស់ក.ស.ច.ស") កថាខណ្ឌ៦។

[21] ដីកាសម្រេចរបស់ក.ស.ច.ស, ឯកសារលេខ D281/3 កថាខណ្ឌ ៧។

[22] ដីកាសម្រេចរបស់ក.ស.ច.ស, ឯកសារលេខ D281/3 កថាខណ្ឌ ៨។

រហស្សនាម TCE-33 ឬដែលមានការជួយជ្រោមជ្រែងរបស់អ្នកជំនាញរូបនេះ ដោយផ្អែកលើសំអាងហេតុថា៖

> ការណ៍ដែលបុគ្គលអ្នកជំនាញម្នាក់នៅក្នុងវិស័យរបស់ខ្លួន ហើយនៅក្នុងពេលប្រកបអាជីពរបស់ខ្លួន បានបញ្ចេញទស្សនៈយោបល់ ដោយផ្អែកលើការស្រាវជ្រាវ និងចំណេះដឹងរបស់ខ្លួនលើប្រធានបទណាមួយនោះ ដោយគ្មានចេតនាអ្វីក្រៅពីនេះ គឺមិនអាចធ្វើឱ្យបុគ្គលទាំងនោះជាបុគ្គលិកលម្អៀងនៅក្នុង [ក.ស.ច.ស] ឡើយ[23]។

១៣ ទោះបី ក.ស.ច.ស បានបដិសេធមិនទទួលយកសំណើសុំតែងតាំងអ្នកជំនាញដែលមានរហស្សនាម TCE-33 ជាអ្នកជំនាញ ដោយសារក្នុងចំណោមចំណុចផ្សេងទៀត គាត់ជាមន្ត្រីដែលបានបំពេញការងារនៅ ក.ស.ច.ស ក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ថាការជំទាស់ទៅនឹងឯករាជភាព ឬភាពមិនលម្អៀងរបស់សាក្សីជំនាញត្រូវបានតុលាការអន្តរជាតិផ្សេងទៀតពិចារណាជាទូទៅថា ពាក់ព័ន្ធនឹងទម្ងន់នៃភស្តុតាងដែលផ្តល់ឱ្យដោយអ្នកជំនាញរូបនោះ ជាជាងភាពទទួលយកបាននៃភស្តុតាងនោះ[24]។ នៅក្នុង *រឿងក្តី Popović និងជនផ្សេងទៀត* ដែល

---

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក David Boyle និង [អ្នកជំនាញ ដែលមានរហស្សនាម TCE-33] និងលើសំណើរបស់ អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី ឯកសារលេខ D402/1/4 ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("សាលដីការបស់អង្គបុរេជំនុំជម្រះ") កថាខណ្ឌ ៣៣។

[24] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popović និងជនផ្សេងទៀត*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រួមគ្នារបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងស្ថានភាពរបស់លោក Richard Butler ជាសាក្សីជំនាញ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-05-88-AR73.2), ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចលើ *រឿងក្តី Popović*"); *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងជនផ្សេងទៀត*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR (សំណុំរឿងលេខ ICTR-99-52-A), ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កថាខណ្ឌ ២៨២ និង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor*, សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីក្នុងការដកចេញភស្តុតាងរបស់សាក្សី Corinne Dufka ដែលបានស្នើសុំដោយអយ្យការ ឬជាជម្រើសម្យ៉ាងទៀត កំហិតវិសាលភាពនៃភស្តុតាងនោះ និង លើសំណើបន្ទាន់របស់អយ្យការសម្រាប់ឱ្យមានសេចក្តីសម្រេច, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SC-SL (សំណុំរឿងលេខ SCSL-03-01-T), ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨, កថាខណ្ឌ ១៧ ; *សូមមើលផងដែរ* វិធាន ៨៧(១) និង (៣) នៃវិធានផ្ទៃក្នុង (ដែលចង្អុលបង្ហាញថា អង្គជំនុំជម្រះអាចបដិសេធភស្តុតាងបានដោយផ្អែកលើភាពមិនពាក់ព័ន្ធ ភាពមិនអាចប្រមូលភស្តុតាងក្នុងពេលវេលាមួយសមស្រប ភាពមិនសក្តិសមដើម្បីបង្ហាញពីអង្គហេតុដែលត្រូវបានចោទប្រកាន់ ឬ ដោយសារមានការបំពារបំពានទៅលើ

មេធាវីការពារក្តីបានជំទាស់ទៅនឹងភាពទទួលយកបាននៃភស្តុតាងរបស់អ្នកជំនាញ ជាអតីតអ្នកវិភាគផ្នែកស៊ើបការសម្លាប់ផ្នែកយោធាសហរដ្ឋអាមេរិក ដែលបំពេញការងារនៅការិយាល័យរដ្ឋអាជ្ញានោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖ "ក្តីបារម្ភពាក់ព័ន្ធនឹងឯករាជភាព និងភាពមិនលម្អៀងរបស់សាក្សី [...] ជាបញ្ហាពាក់ព័ន្ធនឹងទម្ងន់ ពុំមែនភាពអាចទទួលយកបាននោះទេ"[25]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ភាគីដែលបានចោទប្រកាន់ពីភាពលម្អៀង អាចបង្ហាញបានតាមរយៈការសួរដេញដោល ដោយកោះហៅសាក្សីជំនាញរបស់ខ្លួន ឬតាមមធ្យោបាយក្នុងការឆ្លើយតបវិញជាយោបល់របស់អ្នកជំនាញ[26]។ ក្នុងការបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា វិសាលភាពនៃភាពពាក់ព័ន្ធរបស់អ្នកជំនាញ ដែលភាគីបានស្នើសុំទៅនឹងការស៊ើបអង្កេត និងការរៀបចំសំណុំរឿងរបស់រដ្ឋអាជ្ញា អាចនឹងធ្វើឡើងនៅពេលសួរដេញដោល ដោយផ្តល់ឱកាសពេញលេញដល់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការជំទាស់ទៅនឹងភាពទទួលយកបាននៃរបាយការណ៍របស់គាត់[27]។

១៤ នៅក្នុង *រឿងក្តី Milutinović និងជនផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបដិសេធមិនស្តាប់សក្ខីកម្មរបស់អ្នកជំនាញមួយរូបដែលរដ្ឋអាជ្ញាបានស្នើសុំ ដោយសារភាពពាក់ព័ន្ធរបស់គាត់នៅក្នុងការស៊ើបអង្កេត និងការរៀបចំសំណុំរឿងមិនអាចឲ្យអង្គជំនុំជម្រះចាត់ទុកថា យោបល់របស់គាត់មានភាពមិនលម្អៀង ដែលការសន្និដ្ឋាននានាទៅលើយោបល់របស់គាត់ថាមានសារៈសំខាន់ក្នុងការសម្រេចពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធបាន។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អ្នកជំនាញដែលភាគីបានស្នើសុំ "នៅជិតស្និទ្ធនឹងសំណុំរឿងនេះពេក ដែលមិនអាចឲ្យអង្គជំនុំជម្រះលើកយកយោបល់របស់អ្នកជំនាញរូបនោះមកធ្វើ

---

បទដ្ឋានគតិយុត្តិជាមូលដ្ឋានពាក់ព័ន្ធនឹងវិធាននៃការបង្ហាញភស្តុតាង តែថា ភស្តុតាងទាំងអស់អាចទទួលយកបានតាមវិធីផ្សេងទៀត")។

[25] សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារអនុលោមតាមវិធាន ៩៤*ស្ទួន* ពាក់ព័ន្ធនឹងសាក្សីជំនាញ Richard Butler ដែលបានស្នើដោយអយ្យការ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧។

[26] សេចក្តីសម្រេចលើ *រឿងក្តី Popović*, កថាខណ្ឌ ២១ ។

[27] សេចក្តីសម្រេចលើ *រឿងក្តី Popović*, កថាខណ្ឌ ៣១ (ទោះជាយ៉ាងណាក្តី ដោយបានទទួលស្គាល់ថា នៅក្នុងកាលៈទេសៈដ៏តិចតួច អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកអ្នកជំនាញដែលភាគីបានស្នើសុំ ដោយសំអាងថា អ្នកជំនាញរូបនោះ ខ្វះខាតភាពមិនលម្អៀង ឯករាជភាព ឬដោយសារបង្ហាញពីភាពលម្អៀង)។

ជាសំអាងបានទេ”[28]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះមានបំណងស្តាប់សក្ខីកម្មសាក្សីនោះ “ដែលផ្តល់សក្ខីកម្មអំពីអង្គហេតុ តែមិនមែនយោបល់របស់គាត់ទេ”[29]។ នៅក្នុង *រឿងក្តី Đorđević* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានធ្វើការសន្និដ្ឋានដូចគ្នាអំពីបុគ្គលដដែលនោះ[30]។ ទោះជាយ៉ាងណាក្តី បុគ្គលនោះ ដែលត្រូវបានដកចេញមិនឲ្យផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅក្នុង *រឿងក្តី Milutinović និងជនផ្សេងទៀត* និង *រឿងក្តី Đorđević* ត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅក្នុង *រឿងក្តី Milošsević* និង *រឿងក្តី Limaj*[31]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR នៅក្នុង *រឿងក្តី Akayesu* បានរារាំងជនជាប់ចោទម្នាក់ពីសំណុំរឿងមួយមិនឲ្យផ្តល់សក្ខីកម្ម ក្នុងនាមជាអ្នកជំនាញក្នុងសំណុំរឿងមួយទៀត ដោយសារគេពុំអាចធានាឲ្យបានគ្រប់គ្រាន់នូវភាពមិនលម្អៀងរបស់គាត់[32]។ សំណុំរឿងទាំងឡាយខាងលើបង្ហាញថា ការវាយតម្លៃពីគុណសម្បត្តិរបស់អ្នក

---

[28] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងជនផ្សេងទៀត*, ប្រតិចារឹកសវនាការ, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ No.IT-05-87-T), ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦, ទំព័រ ៨៤០ ដល់ ៨៤៤ (ភាសាអង់គ្លេស) និង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងជនផ្សេងទៀត*, សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំការបញ្ជាក់ពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចលើការទទួលយករបាយការណ៍ជំនាញរបស់សាក្សីឈ្មោះ Phillip Coo, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ No.IT-05-87-T), ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ (“សេចក្តីសម្រេចលើ *រឿងក្តី Milutinović*”), កថាខណ្ឌ ១០ (ភាសាអង់គ្លេស)។

[29] សេចក្តីសម្រេចលើ *រឿងក្តី Milutinović*, កថាខណ្ឌ ១១ (ភាសាអង់គ្លេស)។

[30] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Đorđević*, សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីអនុលោមតាមវិធាន ៩៤ *ស្ទួន*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-05-87/1-T), ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩, កថាខណ្ឌ ១៩ (ភាសាអង់គ្លេស)។

[31] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milosević*, សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំការបញ្ជាក់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់អយ្យការដែលសុំឲ្យមានកិច្ចដំណើរការនីតិវិធី *បង្ហាញការពិត (Voir Dire)*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-02-54-T), ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥, កថាខណ្ឌ ២ (ភាសាអង់គ្លេស); *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Limaj និងជនផ្សេងទៀត*, ប្រតិចារឹកសវនាការ, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, សំណុំរឿងលេខ IT-03-66, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៥, ទំព័រ ៥៦៨៣ (ភាសាអង់គ្លេស); សេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញ, ឯកសារ E215, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២។

[32] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu*, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបង្ហាញខ្លួនជនជាប់ចោទមួយរូបជាសាក្សីជំនាញ, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-96-4-T), ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៨; *សូមមើលផងដែរ* សេចក្តីសម្រេចលើ *រឿងក្តី Popović*, កថាខណ្ឌ ២២។

ជំនាញដែលភាគីបានស្នើសុំ និងភាពលម្អៀងរបស់គាត់ត្រូវធ្វើឡើងទៅតាមករណីជាក់ស្តែង ពាក់ព័ន្ធគ្រប់កាលៈទេសៈទាំងអស់[33]។

១៥ អង្គជំនុំជម្រះសាលាដំបូងទទួលយកសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ហើយនឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាអ្នកជំនាញមួយរូប។ អង្គជំនុំជម្រះសាលាដំបូងនឹងវាយតម្លៃអំពីសារៈសំខាន់នៃសក្ខីកម្មនោះពាក់ព័ន្ធនឹងសារណានានា ដែលបានដាក់មកទល់នឹងពេលបច្ចុប្បន្ន ទាក់ទិននឹងភាពមិនលម្អៀង ឬវាយតម្លៃតាមវិធីផ្សេងទៀតទៅលើអ្នកជំនាញដែលមានរហស្សនាម TCE-33 ពាក់ព័ន្ធនឹងការងារពីមុនរបស់គាត់ និងការសាកសួរពិនិត្យភស្តុតាងនៅក្នុងតុលាការដោយអង្គជំនុំជម្រះ និងភាគីទាំងអស់។ ទោះជាយ៉ាងណាក្តី ក្នុងកាលៈទេសៈដែលអ្នកជំនាញ TCE-33 មិនទាន់បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងលក្ខណៈនៃតួនាទីនានាពីមុនៗរបស់គាត់មុនពេលមកបំពេញការងារជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញានោះ អង្គជំនុំជម្រះពិចារណាឃើញថា វាជាការឆាប់រហ័សពេកដែលត្រូវបដិសេធសក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ដោយផ្អែកលើមូលដ្ឋាននេះ។

១៦ ចំពោះការលើកឡើងដែលថា គួរស្តាប់សក្ខីកម្មទៅលើអង្គហេតុពីអ្នកជំនាញដែលមានរហស្សនាម TCE-33 វិញនោះ អង្គជំនុំជម្រះកត់សម្គាល់ថា មានឯកសារជាច្រើននៅក្នុងសំណុំរឿងដែលអ្នកជំនាញ TCE-33 បានដឹងដោយផ្ទាល់ រួមមានការសម្ភាសន៍ដែលគាត់បានធ្វើជាមួយជនជាប់ចោទមួយចំនួន។ ហេតុនេះ អង្គជំនុំជម្រះក៏នឹងស្តាប់សក្ខីកម្មទៅលើអង្គហេតុដែលពាក់ព័ន្ធពីអ្នកជំនាញដែលមានរហស្សនាម TCE-33 នេះផងដែរ។

១៧ ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដែលសុំឱ្យអ្នកជំនាញដែលមានរហស្សនាម TCE-33 ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹង "កិច្ច និងគុណសម្បត្តិ" នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីទាំងអស់អំពីសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះដែលលើកឡើងពីជម្រើសដែលភាគីមាននៅក្នុងក្របខណ្ឌច្បាប់នៅ អ.វ.ត.ក ក្នុងការពិនិត្យមើលទៅលើការប្រមូលព័ត៌មានក្នុងអំឡុងពេលស៊ើបអង្កេតរយៈពេលវែង ហើយដូច្នេះទៅលើវិសាលភាពនៃការសួរដេញដោលដែលអាចអនុញ្ញាតបាននៅក្នុងកម្រិតមួយ ទៅលើបញ្ហាទាំង

[33] សេចក្តីសម្រេចលើ *រឿងក្តី Popović*, កថាខណ្ឌ ៣១។

នេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[34]។ អង្គជំនុំជម្រះបង្គាប់ឱ្យភាគីនានាត្រូវកំណត់សំណួររបស់ខ្លួនតែក្នុងវិស័យនានាដែលពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង០០២ប៉ុណ្ណោះ និងសូមរម្លឹកពីការបែងចែកពេលវេលាសម្រាប់ភាគីនីមួយៗក្នុងការសាកសួរអ្នកជំនាញដែលមានរហស្សនាម TCE-33 ដើម្បីជាប្រយោជន៍នៃសវនាការប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

១៨ ចុងក្រោយ អង្គជំនុំជម្រះណែនាំសហព្រះរាជអាជ្ញាឱ្យចាប់ផ្ដើមការសាកសួរនៅក្នុងសវនាការទៅលើអ្នកជំនាញ ដែលមានរហស្សនាម TCE-33 អនុលោមតាមវិធាន ៩១ និង៩១*ស្ទួន* នៃវិធានផ្ទៃក្នុង។

**ហេតុដូច្នេះ អង្គជំនុំជម្រះ÷**

**បញ្ជាក់ថា** អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាអ្នកជំនាញ និង

**ណែនាំ** សហព្រះរាជអាជ្ញាឱ្យដឹកនាំការសាកសួរអ្នកជំនាញដែលមានរហស្សនាម TCE-33 នៅក្នុងសវនាការ អនុលោមតាមវិធាន ៩១ និង ៩១*ស្ទួន* នៃវិធានផ្ទៃក្នុង។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

[34] សេចក្ដីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារលេខ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ឯកសារ E251, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ២០ ដល់ ២២។